**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល**

# ដំណឹងជ្រើសរើសបុគ្គលិក

**<u>យោង</u>៖**
- កំណត់បង្ហាញលេខ ០៣៥/១៦ ប.ល/ស.វ.ស ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ របស់ផ្នែកបុគ្គលិក នៃ ស.វ.ស។
- ចំណារឯកភាព ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦ របស់ឯកឧត្តមសាកលវិទ្យាធិការ នៃ ស.វ.ស។

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល គឺជាសាកលវិទ្យាល័យបណ្តុះបណ្តាលវិស័យសុខាភិបាល ដែលមានវ័យចំណាស់ជាងគេបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ត្រូវការជ្រើសរើសបុគ្គលិក ចំនួន **០១**រូប សម្រាប់បម្រើការងារនៅផ្នែកមន្ទីរពិសោធន៍រ៉ូដុលហ្វ៍មេរីយើ **(ផលិតមជ្ឈដ្ឋានបណ្តុះមេរោគ)** នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលដែលត្រូវមានភារកិច្ច និងគុណវុឌ្ឍិដូចខាងក្រោម៖

| **ភារៈកិច្ច** | **គុណវុឌ្ឍិ** |
|---|---|
| - ផលិតដបសម្រាប់បណ្តុះមេរោគក្នុងឈាម និង មជ្ឈដ្ឋានបណ្តុះមេរោគតាម SOP ដែលបានសរសេរួចនៅក្នុងមន្ទីរពិសោធន៍។<br>- ធ្វើសន្និធិ បរិក្ខានៅមន្ទីរពិសោធន៍ ដើម្បីធានាថាអ្វីៗគ្រប់យ៉ាងគឺត្រូវបានទុកដាក់បានល្អ តាមលំដាប់ការងារនៅសីតុណ្ហភាពត្រឹមត្រូវ ។<br>- វេចខ្ចប់មជ្ឈដ្ឋានបណ្តុះមេរោគដែលផលិតរួច ដើម្បីបញ្ជូនអោយអតិថិជន និង ដៃគូ។<br>- រៀបចំទុកដាក់ និង ថែរក្សាសម្ភារៈប្រតិកររបស់មន្ទីរពិសោធន៍ តាមទីកន្លែងដែលបានកំណត់ឱ្យមានសណ្តាប់ធ្នាប់ល្អ។<br>- រក្សាអនាម័យ សុវត្ថិភាពក្នុងមន្ទីរពិសោធន៍។<br>- ជួយអ្នកបច្ចេកទេសជាន់ខ្ពស់មន្ទីរពិសោធន៍ក្នុងការធ្វើសំណើសុំសម្ភារៈប្រតិករចាំបាច់សម្រាប់ការផលិត និង ចែកចាយដបសម្រាប់បណ្តុះមេរោគក្នុងឈាម និង មជ្ឈដ្ឋានបណ្តុះមេរោគដ៏ទៃទៀតសម្រាប់មន្ទីរពេទ្យរដ្ឋ។<br>- ជួយអ្នកបច្ចេកទេសជាន់ខ្ពស់មន្ទីរពិសោធន៍ ក្នុងការកំណត់ និង តាក់តែងនូវរាល់វិធីសាស្ត្រប្រតិបត្តិការស្តង់ដារ (SOP ) នានាសម្រាប់ការអនុវត្តការផលិត។<br>- ជួយអ្នកបច្ចេកទេសជាន់ខ្ពស់មន្ទីរពិសោធន៍ក្នុងការរៀបចំទុកដាក់ឯកសារសម្ភារៈ និង ប្រតិករផ្សេងៗ ដែលទាក់ទងនឹងការផលិត ការចែកចាយមជ្ឈដ្ឋានបណ្តុះមេរោគ។<br>- ជួយណែនាំនិស្សិតដែលមកធ្វើកម្មសិក្សានៅមន្ទីរពិសោធន៍។<br>- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំ។ | - កម្រិតមានសញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ ឬ បរិញ្ញាបត្ររង ផ្នែកបច្ចេកទេសមន្ទីរពិសោធន៍ (សញ្ញាបត្រចេញពី ស.វ.ស)<br>- មានបទពិសោធន៍ លើផ្នែកមីក្រុបវិទ្យា<br>- មានចំណេះដឹងផ្នែកកុំព្យូទ័រ Microsoft Office, Internet and Email<br>- មានចំណេះដឹងភាសាអង់គ្លេស និង/ឬ បារាំង នឹងត្រូវបានលើកទឹកចិត្តជាអាទិភាព<br>- មានការប្រាស្រ័យទាក់ទងល្អ រួសរាយ រាក់ទាក់ ស្លូតបូត សុភាពរាបសារ និង គោរពវិន័យ ស.វ.ស ល្អ<br>- មានការទទួលខុសត្រូវក្នុងការងារ និង មានស្មារតីធ្វើការជាក្រុម<br>- មានអាយុយ៉ាងតិច ១៨ឆ្នាំ |

**<u>អត្ថប្រយោជន៍ដែលទទួលបាន</u>៖**

- ប្រាក់ក្នុងបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និង ឱកាសទិវាសិទ្ធនារី (សម្រាប់នារី)
- ប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ (ចំពោះបុគ្គលិកដែលបានបម្រើការងារចាប់ពី ០១ឆ្នាំឡើងទៅ)
- ឱកាសក្នុងការបណ្តុះបណ្តាលជំនាញបន្ត។

**<u>ព័ត៌មានលម្អិត</u>៖**

- បើបេក្ខជនមានចំណាប់អារម្មណ៍ **សូមទំនាក់ទំនងជាមួយផ្នែកបុគ្គលិក នៃ ស.វ.ស ដើម្បីបំពេញពាក្យសុំចូលបម្រើការងារ ឬ អាចទាញយកទម្រង់ពាក្យសុំនេះនៅលើវេបសាយ (www.uhs.edu.kh) រួចផ្ញើមកផ្នែកបុគ្គលិក (បន្ទប់ M109) ឲ្យបានមុនថ្ងៃទី២២ ខែ មេសា ឆ្នាំ២០១៦ វេលាម៉ោង ១៦:០០ រសៀលជាកំហិត។**
- អាស័យដ្ឋានទំនាក់ទំនង៖ ឡូតិ៍លេខ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬ តាមទូរស័ព្ទលេខ **023 430 559 / 089 383 338 / 077 456 070 / 012 961 529 / 015 575 554** E-Mail: orn_samnang@uhs.edu.kh ។

**<u>បញ្ជាក់</u>៖**

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល រក្សាសិទ្ធិក្នុងការធ្វើបញ្ជីឈ្មោះជ្រើសរើសបេក្ខជន (Short List) និង កំណត់ថ្ងៃខែ សម្ភាសន៍ លើកពេលកែប្រែ និង លុបចោលការជ្រើសរើសក្នុងករណីមានភាពមិនប្រក្រតី។
- បេក្ខនារី ត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០១៦

ជ. **ប្រធានផ្នែកបុគ្គលិក**

**អន សំណាង**